**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៣.០១៨.៣៥៨.ស.ជ.ព

ថ្ងៃអង្គារ ១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
# ស្តីពីយុទ្ធនាការស្រលាញ់ប្រាក់រៀល

ធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្សរីករាយ សូមជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ដើម្បីអបអរសាទរពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីខ្មែរ ធនាគារជាតិនៃកម្ពុជានឹងរៀបចំយុទ្ធនាការស្រលាញ់ប្រាក់រៀល ចាប់ពីថ្ងៃចន្ទ ៧រោច ដល់ថ្ងៃសុក្រ ១១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី០១ ដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨។

យុទ្ធនាការនេះ នឹងផ្តល់ឱកាសជូនសាធារណជនដែលមានក្រដាសប្រាក់រៀលចាស់ ទក់ ឬ រហែក អញ្ជើញមកដូរយកក្រដាសប្រាក់រៀលថ្មី នៅតាមបញ្ជរបេឡារបស់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត (លើកលែងស្នាក់ការកណ្តាល) រៀងរាល់ម៉ោងធ្វើការ។

ក្នុងឱកាសនៃពិធីបុណ្យភ្ជុំបិណ្ឌនេះ ធនាគារជាតិនៃកម្ពុជា សូមគោរពជូនពរ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧញ៉ា លោក លោកស្រីទាំងអស់ សូមជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!


ទំនាក់ទំនងព័ត៌មានបន្ថែម

ទូរស័ព្ទ៖ ០២៣-៩៨០-១៩៦

អ៊ីម៉ែល៖ nbccommunication@nbc.org.kh